# Long Beach Unified School District

## មណ្ឌលអប់រំសាលារៀន ឡុងប៊ីច

## Hi Hill នៅ YMCA Camp Oakes

សៀវភៅព័ត៌មានសម្រាប់គ្រួសារ

2024 - 2025

កម្មវិធីសិក្សាក្រៅថ្នាក់សម្រាប់សិស្សថ្នាក់ទី 5

YMCA Camp Oakes

Big Bear City, CA

# តារាងមាតិកា

លិខិតមកពីអគ្គនាយក.................................................................................................................... 3

សេចក្តីសង្ខេបអំពីការធ្វើដំណើរទៅកាន់ Hi Hill នៅ Camp Oakes……....................................................... 4

ព័ត៌មានទូទៅអំពី Hi Hill នៅ Camp Oakes.................................................................................. 5 - 7

គោលការណ៍ច្បាប់ និងនីតិវិធីរបស់ LBUSD នៅ Camp Oakes…………………………………………… 8 - 10

បញ្ជីត្រួតពិនិត្យ មុនពេលចេញដំណើរ……………………………………………………………………...11-12

LONG BEACH UNIFIED SCHOOL DISTRICT Excellence & Equity

the YMCA

Office of the Superintendent
1515 Hughes Way, Long Beach, CA 90810
(562) 997-8242

ខែឧសភា ឆ្នាំ2023

ជម្រាបជូនគ្រួសារនៃសិស្សថ្នាក់បឋមសិក្សា និងថ្នាក់ K-8 ជាទីរាប់អាន

ខ្ញុំមានសេចក្តីរីករាយជម្រាបជូនអ្នកថា ក្នុងចំណែកមួយរបស់កម្មវិធីសិក្សានៅក្នុងមណ្ឌលអប់រំសាលារៀន ឡុងប៊ីច គឺសិស្សថ្នាក់ទីប្រាំទាំងអស់នឹងមានឱកាសចូលរួមមួយសប្តាហ៍ក្នុងកម្មវិធីសិក្សាក្រៅថ្នាក់នៅឯ Camp Oakes ក្បែរក្រុង Big Bear រដ្ឋ កាលីហ្វ័រញ៉ា ចាប់ផ្តើមនៅរដូវស្លឹកឈើធ្លាក់ នៃឆ្នាំ2023 ។ ការចេញដំណើរនេះនឹងធ្វើបន្តតាមទម្លាប់ ដែលធ្លាប់តែមានមកចាប់ផ្តើមនៅខែមេសា នៃឆ្នាំ1948 ដែលមានសិស្សបានចូលរួមនៅ Camp Hi-Hill រាល់ឆ្នាំ ។ គួរអោយស្តាយ ដោយមូលហេតុថា នៅឆ្នាំ2010 គឺជំរុំត្រូវបានបិទ ។ ខ្ញុំមានសេចក្តីរីករាយដោយក្រុមប្រឹក្សាភិបាលអប់រំ ក្នុងពេលថ្មីៗនេះ បានអនុម័តអោយមានការបង្កើតកម្មវិធីសិក្សាក្រៅថ្នាក់ឡើងវិញតាមរយៈការប្រើសេវាដ្ឋានរបស់ YMCA's Camp Oakes ។

ការរៀបចំដំណើរសម្រាប់កម្មវិធីសិក្សាក្រៅថ្នាក់ ដែលរាប់បញ្ចូលទាំងការដឹកជញ្ជូនតាមរថយន្តក្រុងផង គឺនឹងគ្រប់គ្រង និងចេញថ្លៃបង់ដោយក្រសួងថ្នាក់លើ ប៉ុន្តែ អ្នកនឹងទទួលការស្នើសុំអោយផ្តល់ព័ត៌មានអំពីការចុះឈ្មោះ ដែលចាំបាច់ ដើម្បីអោយការរៀបចំដំណើរមានភាពត្រឹមត្រូវសម្រាប់សិស្សរបស់អ្នក ។ សាលារៀននីមួយៗ ដែលនឹងចេញដំណើរ គឺប្រើថ្ងៃខែខុសៗពីគ្នាទូទាំងឆ្នាំសិក្សា ដូច្នេះ សៀវភៅដៃ Camp Oakes សម្រាប់គ្រួសារ ត្រូវបានសរសេរឡើង ដើម្បីបញ្ជាក់ថា ការទៅពិនិត្យ គឺនឹងនាំមកជាបទពិសោធន៍ដ៏ល្អសម្រាប់សិស្សទាំងអស់មែន រួមទាំងគ្រូបង្រៀន និងបុគ្គលិកប្រចាំ LBUSD ទៀតផង ដែលពួកគេនឹងចេញដំណើរដែរទៅជាមួយសិស្ស ។ ដោយមានការគាំទ្រពីអ្នក ខ្ញុំមានជំនឿថា ការចេញដំណើរអស់រយៈពេលមួយសប្តាហ៍នេះទៅកាន់ជើងភ្នំ គឺនឹងបន្តនូវការផ្តល់បទពិសោធន៍មួយដ៏ល្អ ដែលបង្កើនចំណេះរបស់ពួកគេអំពីធម្មជាតិ និងវិទ្យាសាស្ត្រ ដោយនៅពេលជាមួយគ្នានោះដែរ គឺជួយកសាងជំនាញមិត្តភាព និងការលើកកម្ពស់មកកាន់ខ្លួនឯង ។

បើអ្នកមានសំណួរ ឬក្តីកង្វល់អ្វី សូមទាក់ទងលោក Jeff Wood ជានាយកគ្រប់គ្រងកម្មវិធីសិក្សាក្រៅថ្នាក់ នៅការិយាល័យបឋមសិក្សា និង TK-8 តាមលេខទូរស័ព្ទ (562) 997-8247 ឬ jwood@lbschools.net ។

ដោយសេចក្តីស្មោះ

Jill A. Baker, Ed. D
អគ្គនាយកសាលារៀន

## Hi Hill Outdoor នៅ Camp Oakes
## សេចក្តីសង្ខេបអំពីការធ្វើដំណើរ

### គោលដៅ

ការធ្វើដំណើរសម្រាប់សិស្សថ្នាក់ទី5 ទៅកាន់ Hi Hill នៅ Camp Oakes គឺប្រព្រឹត្តតាមគម្រោងប្តេជ្ញាចិត្តមួយរបស់មណ្ឌលអប់រំសាលារៀន ឡុងប៊ីច ក្នុងការផ្តល់ឱកាសជាសមធម៌សម្រាប់យុវវ័យរុករកមើលអំពីពិភពលោក ក្រៅតែពីសហគមន៍របស់ពួកគេ ។ ឱកាសនេះផ្តល់ឱកាសសម្រាប់សិស្សថ្នាក់ទី5 ម្នាក់ៗរស់នៅ និងសិក្សាអំពីអ្វីនៅតាមទីវាលសម្រាប់រយៈពេលមួយសប្តាហ៍ ។ ការស្រាវជ្រាវបានបង្ហាញថា ការសិក្សានៅតាមទីវាល គឺនាំមកជាប្រយោជន៍ច្រើនយ៉ាងណាស់ ។ វាអាចបង្កើន**កម្លាំងទឹកចិត្ត ការលើកកម្ពស់មកកាន់ខ្លួនឯង ជំនាញមិត្តភាព ទំនាក់ទំនង ទឹកចិត្តប្រឹងប្រែង និងសុខភាពរូបកាយ** ដែលគាំទ្រដល់ការយល់ឃើញតែអំពីចំណុចល្អៗមកកាន់ការសិក្សា និងបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការធ្វើសហប្រតិបត្តិការ ។

### តើសិស្សនឹងរៀនអំពីអ្វី

Hi Hill នៅ YMCA Camp Oakes ផ្តល់ឱកាសពិសេសសម្រាប់ការរៀនមកកាន់សិស្ស ដើម្បីអោយពួកគេចេះរាប់អានជាមួយមនុស្សគ្រប់ឋានៈទាំងអស់ ដែលជាជំនាញយកមកប្រើក្នុងសាលារៀន និងពេញមួយជីវិតរបស់ពួកគេ ។ ការរស់នៅក្នុងបរិយាកាសកម្មវិធីសិក្សាក្រៅថ្នាក់ចំនួនពេល 24 ម៉ោង ក្នុងមួយថ្ងៃ គឺសិស្សនឹងមានឱកាសស្ទុះលូតលាស់ក្នុងការយល់ដឹង និងបណ្តុះអារម្មណ៍ស្របតាមគោលដៅក្នុងលក្ខណៈជាភាពពិតច្បាស់លាស់ ។ នៅ Hi Hill នៅ YMCA Camp Oakes គឺសិស្សទទួលមុខងារខុសត្រូវថ្មី គោរព និងយល់តម្លៃមិត្តភាពរបស់មិត្តរួមថ្នាក់ និងគ្រូបង្រៀនរបស់ពួកគេតាមរយៈទទួលបទពិសោធន៍ជាមួយធម្មជាតិ និងអ្វីផ្សេងៗដ៏ស្រស់ស្អាតនៅតាមទីវាល ។ សិស្សនឹងអនុវត្តតាមការប្រើជំនាញមិត្តភាព ការគ្រប់គ្រងខ្លួនឯង និងការបង្កើនផ្នត់គំនិតរបស់ពួកគេតាមរយៈការរស់នៅជាបទពិសោធន៍ប្រចាំថ្ងៃ ដែលភ្ជាប់ដោយការចេះគិតគូរទៅកាន់អ្នកដទៃ និងការយកចិត្តទុកដាក់ចំពោះខ្លួនឯង ។

នៅតាមជំរុំសិក្សាក្រៅថ្នាក់ គឺសិស្សសិក្សាផ្ទាល់ដៃអំពីវិទ្យាសាស្ត្រ ដូចជា៖ ទ្រុងទ្រាយដី រុក្ខជាតិ សត្វព្រៃ ភូគព្ភសាស្ត្រ ថ្ម រ៉ែ ហ្វូងផ្កាយ ភូតគាមសាស្ត្រ អាកាសធាតុ ប្រភពទឹក និងអ្វីផ្សេងៗទៀតទាក់ទងវិទ្យាសាស្ត្រ និងគោលគំណិតជំនាញមិត្តភាពតាមរយៈទទួលឱកាសជាច្រើនសម្រាប់ការសិក្សាដោយធ្វើការពិសោធន៍ ។ កម្មវិធីសិក្សា ដែលបានលើកបង្ហាត់ គឺជាចំណែកមួយដ៏សំខាន់សម្រាប់បទពិសោធន៍ផ្នែកវិទ្យាសាស្ត្រសម្រាប់កូនរបស់អ្នក ។ កម្មវិធីសិក្សា គឺទាក់ទាញសិស្សចេញពីក្នុងថ្នាក់ទៅកាន់ថ្នាក់មួយផ្សេង ដែលសិស្សសិក្សាតាមរយៈធ្វើ និងទទួលបទពិសោធន៍ផ្ទាល់ដៃមកលើអ្វីគ្រប់យ៉ាង ។ សាលារៀននៅតាមទីវាលផ្តល់បទពិសោធន៍ដ៏រំភើប និងរីករាយសម្រាប់សិស្ស ។ ដោយមូលហេតុនេះ សិស្សរៀនកាន់តែលឿន យល់កាន់តែច្បាស់ និងទទួលចំណេះបានកាន់តែច្រើនអំពីអ្វី ដែលពួកគេបានរៀនមក ។

Hi Hill នៅ YMCA Camp Oakes មានសកម្មភាពជាច្រើនសម្រាប់សិស្ស ដែលរាប់បញ្ចូលទាំង៖ ការបាញ់ព្រួញ គំនូរ សិល្បៈ ការស្ទូចត្រី ល្បែងលេងជុំគ្នា ហ្គលហ្វ៍ កីឡាបាល់ទះ ការរុករកធម្មជាតិ ការដើរកំសាន្តជើងភ្នំ ការជិះទូកខាន្ទូ ការលេងបាល់ ហ្គាហ្គា ការឡើងកម្ពស់ថ្ម ការប្រជែងលោតអន្ទាក់ ការសម្លឹងមើលទៅកាន់ហ្វូងផ្កាយ ការដុត និងអាំងភ្លើងភ្ជាប់ដោយការច្រៀង និងការនិយាយរឿងកំប្លែងខ្លីៗ ដែលរួមដោយសកម្មភាពជាច្រើនផ្សេងៗទៀត ។ សកម្មភាពទាំងអស់នេះនឹងផ្តល់ឱកាសអោយសិស្សបង្កើនចំណេះ ការចេះប្រឹងប្រែងដោយខ្លួនគេ និងការបំពេញកិច្ចការរួមគ្នា ដើម្បីសិក្សាអំពីអ្វីពិសេសៗនៅតាមទីវាល ។

មានមាតាបិតា និងជីដូនជីតាជាច្រើននាក់ ដែលធ្លាប់រៀននៅសាលាបឋមសិក្សាក្នុង LBUSD គឺនៅតែចងចាំបាននៅឡើយអំពីអនុស្សាវរីយ៍ពេញមួយសប្តាហ៍ ដែលពួកគេបានទៅចូលរួមក្នុងកម្មវិធីសិក្សាក្រៅថ្នាក់ ហើយយើងដឹងថា សិស្សរបស់អ្នកក៏នឹងបានទទួលដូច្នេះដែរ ។

# Hi Hill Outdoor នៅ YMCA Camp Oakes

## ព័ត៌មានទូទៅ

### ទីតាំងសេវាដ្ឋាន

កម្មវិធីសិក្សាក្រៅថ្នាក់របស់មណ្ឌលអប់រំសាលារៀន ឡុងប៊ីច ស្ថិតនៅ Long Beach YMCA′s Camp Oakes ក្នុងជួរភ្នំ San Bernardino ក្បែរក្រុង Big Bear City ។ វាមានទំហំប្រហែល 235 អេគ័រ ក្នុងឱទ្យានព្រៃជាតិ San Bernardino National Forest ដែលមានកម្ពស់ 7,200 ហ្វីត ។ Camp Oakes មានចម្ងាយប្រហែល 120 ម៉ៃ ពីក្រុង Long Beach ឬ 15 នាទីពីក្រុង Big Bear City ។

### តម្លៃចូលរួម

ការធ្វើដំណើរទៅកាន់ Hi Hill នៅ YMCA Camp Oakes នឹងមានការចេញបង់ពេញថ្លៃដោយមណ្ឌលអប់រំសាលារៀន ឡុងប៊ីច ។ **គ្មានត្រូវការបង់ថ្លៃអ្វីទេសម្រាប់ការចូលរួម** ។ គ្រួសារមានមុខងារទទួលខុសត្រូវមកលើការផ្តល់សំលៀកបំពាក់ និងកម្រាលភួយត្រឹមត្រូវសម្រាប់សិស្សរបស់ពួកគេ ។ គ្រួសារ ដែលត្រូវការជំនួយផ្នែកសំលៀកបំពាក់ ឬកំរាលភួយ គឺត្រូវទាក់ទងនាយកគ្រប់គ្រងកម្មវិធីសិក្សាក្រៅថ្នាក់ប្រចាំ LBUSD គឺលោក Jeff Wood នៅតាម jwood@lbschools.net ឬនាយកនៅតាមសាលារៀនរបស់ពួកគេ ដើម្បីពិគ្រោះអំពីសេចក្តីត្រូវការរបស់ពួកគេ ។

### ការដឹកជញ្ជូន

មណ្ឌលអប់រំសាលារៀន ឡុងប៊ីច នឹងផ្តល់ការដឹកជញ្ជូនតាមរយៈរថយន្តក្រុងទៅមកពី Hi Hill នៅ YMCA Camp Oakes នៅថ្ងៃចេញដំណើរពីសាលារៀន និងនៅថ្ងៃត្រឡប់មកវិញ ដោយគ្មានបង់ថ្លៃអ្វីទាំងអស់ ។ ***បើមានមូលហេតុអ្វី ដែលកូនរបស់អ្នកត្រូវការត្រឡប់មកផ្ទះវិញក្នុងពេលកំពុងស្នាក់នៅក្នុងជំរុំសិក្សាក្រៅថ្នាក់ គឺមាតាបិតានឹងប្រហែលជាហៅអោយមកដកយកសិស្សចេញ ដោយបង់ថ្លៃធ្វើដំណើរខ្លួនឯង ។****

### កេរ្តិ៍ឈ្មោះរបស់ជំរុំសិក្សាក្រៅថ្នាក់

YMCA Camp Oakes ជាប់ឈ្មោះទទួលស្គាល់ពេញច្បាប់ដោយអង្គការ American Camp Association ដែលមានន័យថា ទីតាំងត្រូវបានទទួលការស្ទង់វាស់មើលដោយអ្នកជំនាញការ ដើម្បីតម្រូវស្របតាមស្តង់ដារផ្នែកសុខភាព និងសុវត្ថិភាពនៅតាមឧស្សាហកម្មជាង 300 ចំណែក ដូចជា៖ ការគ្រប់គ្រងនៅពេលមានគ្រាអាសន្ន ការអប់រំកុមារ ការហែលទឹក និងការមើលថែសុខភាព ជាដើម ។ ក្រសួងសុខាភិបាលប្រចាំ San Bernardino ខោនធី និងក្រសួងផ្សេងៗរបស់រដ្ឋ/ខោនធី ក៏បានធ្វើការត្រួតពិនិត្យដែរ ស្របតាមតម្រូវការផ្សេងៗ ។

### ការដាក់អោយសិស្សគេងតាមបន្ទប់ខ្ទម

គ្រូបង្រៀនរបស់សិស្សនឹងរៀបចំបន្ទប់គេងសម្រាប់សិស្សជាក្រុម ស្របតាមភេទ មុនដល់ពេលចេញដំណើរ ។ គ្រូបង្រៀននឹងប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីរៀបដាក់អោយមានជាមិត្តដ៏ស្និទ្ធស្នាលម្នាក់សម្រាប់ស្នាក់នៅជុំគ្នាជាមួយសិស្ស ។ ប៉ុន្តែ មិនមែនធានាថា មិត្តទាំងអស់នឹងនៅជុំគ្នាបាននោះទេ ។ ខ្ទមនឹងមានសិស្សមកពីបន្ទប់រៀនផ្សេងៗ ឬមកពីសាលារៀនផ្សេងៗក្នុង LBUSD ដែលពួកគេទៅចូលរួមក្នុងពេលសប្តាហ៍ដូចគ្នា ដែលនឹងផ្តល់ឱកាសសម្រាប់សិស្សរាប់អានមិត្តថ្មី ។

### ការមើលខុសត្រូវនៅតាមខ្ទម

ក្រុមសិស្សនៅតាមខ្ទមនឹងមានការមើលខុសត្រូវដោយទីប្រឹក្សាជាមនុស្សធំ ស្របតាមការចែងតម្រូវជាចំនួនដោយអង្គការ American Camping Association ។ បុគ្គលិកទាំងអស់ត្រូវបានទទួលការជ្រើសរើសឡើង ដោយមូលហេតុថា ពួកគេមានសមត្ថភាពបំពេញកិច្ចការជាមួយកុមារ និងបានទទួលការហ្វឹកហ្វឺនច្រើនលើកមុននឹងដល់ពេលក្នុងសប្តាហ៍ចេញដំណើរសម្រាប់កម្មវិធីសិក្សាក្រៅថ្នាក់ ។ នាយកគ្រប់គ្រងជំរុំ គឺជាបុគ្គលិកមានការប្តេជ្ញាចិត្ត ដែលភ្ជាប់ដោយបទពិសោធន៍ជាច្រើនឆ្នាំក្នុងការបំពេញកិច្ចការជាមួយកុមារនៅតាមជំរុំសិក្សាក្រៅថ្នាក់ ។ បុគ្គលិកនៅតាម YMCA Camp Oakes និងបុគ្គលិកក្នុង LBUSD ទាំងអស់មានមុខងារ

ជាអ្នកធ្វើសេចក្តីរាយការណ៍ ស្របតាមតម្រូវការពីច្បាប់ ។

## ការរំលោភសិទ្ធិកុមារ

បុគ្គលិកក្នុង LBUSD បានទទួលការតម្រូវអោយធ្វើជាអ្នករាយការណ៍អំពីការសង្ស័យមកលើការរំលោភសិទ្ធិកុមារ (ដូចជា៖ ការវាយធ្វើបាប ការបំបាក់ទឹកចិត្ត ការជេរស្តី និង/ឬ ការមិនយកចិត្តទុកដាក់មើលថែ) ទៅកាន់អាជ្ញាធរត្រឹមត្រូវភ្លាមៗ ។

## ការនឹកផ្ទះ

ការនៅឆ្ងាយពីផ្ទះចំនួនពេលមួយសប្តាហ៍អាចបង្កជាបញ្ហាមួយសម្រាប់កុមារគ្រប់អាយុទាំងអស់ ។ នៅពេលកុមារនៅឆ្ងាយពីផ្ទះជាលើកទីមួយ គឺពួកគេនឹកផ្ទះ ។ យើងស្នើសុំអោយអ្នកជួយអប់រំណែនាំកូនរបស់អ្នក មុននឹងដល់ពេលចេញដំណើរ ។ បញ្ជាក់ប្រាប់ពួកគេអោយដឹងថា អ្នកមានជំនឿច្បាស់លាស់មកលើពួកគេក្នុងការដោះស្រាយជាមួយបទពិសោធន៍ថ្មីនេះនៅតាមជំរុំសិក្សាក្រៅថ្នាក់ ។ ធ្វើការផ្តោតមកលើតែចំណុចល្អៗបានហើយអំពីជំរុំសិក្សាក្រៅថ្នាក់ ការរាប់អានមិត្តថ្មី សកម្មភាពដែលពួកគេនឹងពេញចិត្តចូលរួមជាមួយ និងអំពីការកោតសរសើរពីអ្នកមកលើពួកគេ នៅពេលណាពួកគេធ្វើបានសម្រេច ។ នៅពេលទៅដល់ជំរុំសិក្សាក្រៅថ្នាក់ហើយ គឺបុគ្គលិកនឹងធ្វើការដោះស្រាយបញ្ហានឹកផ្ទះ – ដោយធ្វើអោយសិស្សនៅជាប់រវល់ជានិច្ច និងទទួលនូវការសប្បាយ ។ យើងសូមជម្រុញអោយមានការសរសេរសំបុត្រពីផ្ទះទៅ ដើម្បីអោយកូនរបស់អ្នកអានស្តាប់ពីអ្នក ដែលជាមធ្យោបាយលើកទឹកចិត្ត ។ សូមចងចាំថា Camp Oakes បានបង្កើតជាបទពិសោធន៍ដ៏ល្អៗសម្រាប់សិស្សរាប់ពាន់នាក់អស់រយៈពេលជាយូរឆ្នាំមក ហើយយើងដឹងថា សិស្សរបស់អ្នកក៏នឹងបានទទួលដូច្នេះដែរ ។

## ការត្រៀមទុកសម្រាប់ជំរុំសិក្សាក្រៅថ្នាក់

ជំរុំសិក្សាក្រៅថ្នាក់ផ្តល់ភាពរីករាយ និងឱកាសសម្រាប់សិស្សរបស់អ្នកកសាងជំនឿទុកចិត្តក្នុងខ្លួន និងបង្កើនសមត្ថភាពទំនាក់ទំនង ។ នេះក៏ជាឱកាសមួយផងដែរសម្រាប់ការរៀនធ្វើជាភាពឯករាជ្យ និងទំនួលខុសត្រូវ ។ ពួកគេនឹងរៀនថែរក្សាខ្លួន រៀបចំកម្រាលគួយ និងមើលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួនឯង ។ នៅផ្ទះ យើងសូមជម្រុញអោយមាតាបិតាបណ្តោយអោយសិស្សរៀបចំ និងប្រមូលទុកដាក់របស់ប្រើប្រាស់រួមគ្នា ដោយមើលតាម ***<u>បញ្ជីត្រួតពិនិត្យ មុនពេលចេញដំណើរ</u>*** ។ ការធ្វើដូច្នេះ កូនរបស់អ្នកអាចចាប់ផ្តើមរៀនបានអំពីការយកចិត្តទុកដាក់ចំពោះខ្លួនឯង និងវាជួយធ្វើអោយមានភាពរីករាយផងអំពីជំរុំសិក្សាក្រៅថ្នាក់ ។ សិស្សមិនអាចរៀបខ្ចប់ដាក់អាហារ និង/ឬគ្រាប់ស្ករបានទេ ។ សូមជួយលើកទឹកចិត្តសិស្ស និងគិតគូរមើលតែអំពីអ្វី ដែលនឹងកើតមានឡើងជាបទពិសោធន៍ល្អក្នុងពេលបន្តបន្ទាប់ទៅមុខ ។ សូមមេត្តាលៃលកធ្វើយ៉ាងណា ដើម្បីអោយអ្នក និងកូនរបស់អ្នកយកចិត្តទុកដាក់ ដោយ**មិន**យករបស់របរដូចតទៅនេះទៅកាន់ជំរុំសិក្សាក្រៅថ្នាក់នៅ Camp Oakes៖

## របស់របរហាម - <u>កុំយកមកជាមួយ!</u>

- គ្រឿង អេឡិចត្រូនិច **<u>ជាប្រភេទអ្វីក៏ដោយ</u>**៖
    - ទូរស័ព្ទដៃ ឬឧបករណ៍ អេឡិចត្រូនិច ផ្សេងៗ
    - ឡេបថប ថេប្លិត iPod's ឧបករណ៍ស្តាប់ត្រចៀក ឬ នាឡិកា Smart Watch
    - ឧបករណ៍កាន់លេង ហ្គេម
- ដែកកេះ ឬកាំជ្រួច
- កាំបិត ឬពូថៅដៃ
- កាំភ្លើង
- ថ្នាំជក់
- គ្រឿងញៀនខុសច្បាប់
- អាហារ
- ស្ករទំពារ ឬ គ្រាប់ស្ករ
- ថ្នាំបាញ់សំអាតក្លិនខ្យល់

របស់របរហាមដាក់មក គឺនឹងប្រមូលទុក កត់ឈ្មោះសិស្សនៅពីលើ និងរក្សាទុកក្នុងជំរុំសិក្សាក្រៅថ្នាក់ ទំរាំដល់ថ្ងៃចេញដំណើរត្រឡប់ទៅវិញ ។ របស់របរប្រមូលបានមក គឺនឹងប្រគល់ ស្របតាមឱកាសត្រឹមត្រូវ ទៅកាន់បុគ្គលិកសាលារៀន និងមាតាបិតា បន្ទាប់ពីបានត្រឡប់មកដល់ផ្ទះវិញ ។ LBUSD និង/ឬ YMCA គ្មានមុខងារទទួលខុសត្រូវអ្វីទេមកលើរបស់របរបាត់បង់ ឬបែកបាក់ក្នុងដំណើរការនេះ ។

## ព័ត៌មានទាក់ទងនៅពេលសិស្សទៅដល់ Hi Hill នៅ YMCA Camp Oakes

### <u>មធ្យោបាយទាក់ទងជាមួយកូនរបស់អ្នក</u>

គ្រួសារទទួលការស្វាគមន៍អោយផ្ញើជាសំបុត្រទៅកាន់កូនរបស់ពួកគេ នៅពេលកំពុងស្នាក់នៅជំរុំសិក្សាក្រៅថ្នាក់ ។ សិស្សពេញចិត្តក្នុងការទទួលសំបុត្រ ប៉ុន្តែសូមមេត្តាកុំសរសេររៀបរាប់អំពីបញ្ហាស្មុគ្រស្មាញក្នុងផ្ទះ ឬអំពីមនុស្សក្នុងគ្រួសារ ដែលមានការនឹករលឹកទៅកាន់ពួកគេអោយសោះ ។ រៀបរាប់តែអំពីដំណឹងល្អៗបានហើយ ។ ការផ្ញើសំបុត្រនៅមុនថ្ងៃចេញដំណើរ គឺនឹងបញ្ជាក់ថា កូនរបស់អ្នកនឹងបានទទួលសំបុត្រក្នុងសប្តាហ៍ចំណាយក្នុងជំរុំសិក្សាក្រៅថ្នាក់ ។ ការផ្ញើសំបុត្រ និងប៉ូស្តកាដ ដែលមាន ស្តែម គឺផ្ញើនៅមុនថ្ងៃចេញដំណើរ ដែលនឹងបង្កើតឱកាសកាន់តែច្រើនសម្រាប់សិស្សរបស់អ្នកអាចទទួលវាបានទាន់ពេលវេលា ។ សូមចងចាំថា ពេលវេលានៅជំរុំសិក្សាក្រៅថ្នាក់ គឺដើរយឺតជាងពេលវេលានៅក្នុងក្រុង ។ ដូច្នេះ សូមទុកពេលវេលាចំនួន 4 ថ្ងៃ ដើម្បីអោយសំបុត្រផ្ញើបានទៅដល់សិស្ស ។ <u>**កុំផ្ញើ**</u>កញ្ចប់ទាំងឡាយណា ដែលមានអាហារ ឬគ្រាប់ស្ករជាប្រភេទអ្វីក៏ដោយ ។ Camp Oakes ស្ថិតនៅភ្នំ ហើយអាហារ គឺជាការប្រកាសហៅអោយសត្វល្អិតៗ និងសត្វព្រៃមកទទួលផ្ញើជាចំណី ។

យើងស្នើសុំអោយមាតាបិតាផ្តល់សំបុត្រទៅកាន់គ្រូបង្រៀន មុននឹងដល់ថ្ងៃចេញដំណើរ ។ បន្ទាប់មក គ្រូបង្រៀននឹងចែកសំបុត្រទៅកាន់សិស្សនៅម៉ោងទទួលអាហារពេលព្រឹកក្នុងសប្តាហ៍ស្នាក់នៅក្នុងជំរុំសិក្សាក្រៅថ្នាក់ ។

សូមមេត្តាផ្ញើសំបុត្ររបស់អ្នកទៅកាន់អាស័យដ្ឋានដូចតទៅ៖

<u>**បើផ្ញើតាមរយៈប្រៃសណីយ - US Postal Service**</u>

*YMCA Camp Oakes*
*ឈ្មោះរបស់សិស្ស - ថ្ងៃខែទៅលេងជំរុំសិក្សាក្រៅថ្នាក់*
*P.O. Box 452*
*Big Bear City, CA 92314*

<u>**បើផ្ញើតាមរយៈ UPS ឬ Fed Ex**</u>

*YMCA Camp Oakes*
*ឈ្មោះរបស់សិស្ស - ថ្ងៃខែទៅលេងជំរុំសិក្សាក្រៅថ្នាក់*
*47400 Monte Vista Drive*
*Big Bear City, CA 92314*

# គោលការណ៍ច្បាប់ និងនីតិវិធីរបស់ Hi Hill នៅ YMCA Camp Oakes

## ការប្រើថ្នាំពេទ្យនៅជំរុំសិក្សាក្រៅថ្នាក់

កុំរៀបដាក់ថ្នាំពេទ្យអោយសោះ រាប់បញ្ចូលផងទាំងថ្នាំពេទ្យទិញ ដោយគ្មានបញ្ជាពីវេជ្ជបណ្ឌិតផង នៅក្នុង វ៉ាលីស នៃកូនរបស់អ្នក ។

**ថ្នាំពេទ្យទាំងអស់ (ទាំងថ្នាំមានបញ្ជា និងគ្មានបញ្ជាពីវេជ្ជបណ្ឌិតក្តី) គឺត្រូវធ្វើដាក់បញ្ជូន រួមដោយឯកសារតម្រូវផ្សេងៗទៀតផង ទៅកាន់អ្នកគ្រូពេទ្យសាលារៀន អោយបានយ៉ាងហោចណាស់មួយសប្តាហ៍មុនពេលចេញដំណើរ ។**

អ្នកគ្រូពេទ្យនឹងសើរើមើលថ្នាំពេទ្យទាំងអស់ និងក្រដាសចុះឈ្មោះបំពេញតាម អនឡាញ ។ បើសិស្សរបស់អ្នកត្រូវការប្រើថ្នាំពេទ្យនៅពេលកំពុងស្នាក់នៅជំរុំសិក្សាក្រៅថ្នាក់ គឺថ្នាំពេទ្យមួយមុខៗត្រូវមានការឆ្លើយបំពេញក្នុងក្រដាស "Medication at School" ដោយវេជ្ជបណ្ឌិតនៃសិស្សរបស់អ្នក ។ ថ្នាំពេទ្យត្រូវមានដាក់ក្នុងដបត្រឹមត្រូវមកពីឱសថស្ថាន ដោយមានឈ្មោះនៃកូនរបស់អ្នកនៅពីលើ និងការបង្ហាញច្បាស់លាស់ផងដោយវេជ្ជបណ្ឌិតអំពីរបៀបប្រើ ។ **គ្មានថ្នាំពេទ្យណា** <u>(រាប់ទាំងថ្នាំវីតាមីនផង) ដែលអាចរក្សាទុកក្នុងខ្លួមបានទេ ។</u> អ្នកគ្រូពេទ្យក្នុងជំរុំសិក្សាក្រៅថ្នាក់ នឹងដាក់ថ្នាំពេទ្យទាំងអស់អោយសិស្សប្រើ ។ សូមមេត្តារៀបដាក់ថ្នាំពេទ្យដែលអាចប្រើបានចំនួន 10 ថ្ងៃ ដើម្បីអោយយើងត្រៀមទុកសម្រាប់កាលៈទេសៈអ្វីមួយ ដែលអាចកើតឡើងបាន (ដូចជា៖ ការផ្លាស់ប្តូរអាកាសធាតុ ជាដើម) ។ សូមមេត្តាជួបអ្នកគ្រូពេទ្យប្រចាំសាលារៀនរបស់អ្នក ដើម្បីទទួលក្រដាសបំពេញ និង ឬ បើមានសំណួរផ្សេងៗ ។

## ទូរស័ព្ទដៃ/ទំនាក់ទំនងជាមួយសិស្សរបស់អ្នក

សូមមេត្តារក្សាទុកទូរស័ព្ទដៃ ថេប្លិត និងនាឡិកា smart watch នៅផ្ទះ ដោយមូលហេតុថា មិនអាចយកទៅជំរុំសិក្សាក្រៅថ្នាក់ជាមួយបានទេ ។ សូមជម្រុញអោយគ្រួសារធ្វើការទាក់ទងជាមួយសិស្សតាមរយៈសំបុត្រ ដូចបានធ្វើការរៀបរាប់រួចមក ។ គ្រួសារក៏អាចផ្តល់ជាសំបុត្រផ្ទាល់ដៃទៅកាន់គ្រូបង្រៀននៃសិស្សរបស់ពួកគេបានដែរ ក្រែងលសំបុត្រ ដែលផ្ញើ គឺមិនបានទៅដល់ទាន់ពេលវេលា ។ សូមមេត្តាកុំផ្ញើអាហារ គ្រាប់ស្ក ឬរបស់របរផ្សេងៗ ដែលទទួលការហាមឃាត់ ។

## ការមើលថែសុខភាព

សិស្ស ដែលមានជម្ងឺ គឺមិនអាចធ្វើដំណើរទៅកាន់ជំរុំសិក្សាក្រៅថ្នាក់បានទេ ។ បើសិស្សមានជម្ងឺ គឺ Camp Oakes នឹងមានបន្ទប់សុខភាពមួយ ដែលមានអ្នកគ្រូពេទ្យនៅជាមួយ ។ បើមានជម្ងឺ គឺសិស្សនឹងស្នាក់នៅបន្ទប់នោះ ស្របត្រឹមត្រូវតាមពេលវេលា ។ បើយល់ថា ចាំបាច់ គឺមាតាបិតា/អាណាព្យាបាលនឹងទទួលការហៅអោយទៅដកយកសិស្សរបស់ពួកគាត់មកផ្ទះវិញ ។ បើសិស្សរបស់អ្នកមានជម្ងឺ មុនពេលចេញដំណើរ គឺអ្នកគ្រូពេទ្យនឹងធ្វើការបញ្ជាក់ថា គេមានសុខភាពមាំមួនមែនដែលអាចចូលរួមក្នុងការធ្វើដំណើរទៅកាន់ជំរុំសិក្សាក្រៅថ្នាក់បាននៅតាមភ្នំក្នុងរយៈពេលមួយសប្តាហ៍ ដែលពោរពេញដោយការប្រើសកម្មភាពច្រើន ។

សិស្សទាំងឡាយណា ដែលបង្ហាញបញ្ហាសុខភាព ដូចជា៖ មានកំដៅខ្លួនជាកម្រិត 100.4 អង្សា ឬខ្ពស់ ឈឺបំពង់ក ក្អួត រាគ រមាស់ស្បែកខ្លាំង មានរបួស របកស្បែក និង/ឬ មានចៃក្បាល (ពងចៃ ឬចៃរស់រវើក) គឺនឹងទទួលការដកឈ្មោះចេញពីការចូលរួម ដើម្បីការពារសុខភាពដល់អ្នកដទៃ ។

បើមានភាពអាសន្ន ឬសេចក្តីត្រូវការពិសេសអ្វីកើតឡើង គឺយើងមានវេជ្ជបណ្ឌិត និងមន្ទីរ គ្លីននិក នៅក្រុង Big Bear ។ បើមានការរងរបួស នៅពេលកំពុងនៅក្នុងជំរុំសិក្សាក្រៅថ្នាក់ គឺយើងនឹងប្រើវិធានការចាំបាច់ ដើម្បីយកចិត្តទុកដាក់មកលើការមើលថែត្រឹមត្រូវ ដែលរាប់បញ្ចូលទាំង - ការព្យាបាលដោយបុគ្គលិកចំពោះរបួសស្រាលៗ ហៅមាតាបិតា/អាណាព្យាបាល ដើម្បីស្នើសុំយោបល់អំពីការព្យាបាល ហៅវេជ្ជបណ្ឌិតនៅតាមកន្លែងក្បែរៗ ឬ ដឹកសិស្សទៅជួបវេជ្ជបណ្ឌិត ឬមន្ទីរព្យាបាលជាបន្ទាន់ ។ មាតាបិតា ដែលមានសិស្សមានកំដៅខ្លួនជាកម្រិត 100.4 អង្សា ឬលើស គឺនឹងទទួលការទាក់ទងទៅកាន់ ហើយសិស្សនឹងប្រហែលជាមានឈ្មោះដកចេញពីជំរុំសិក្សាក្រៅថ្នាក់ ។

សំខាន់ណាស់ ដែលអ្នកត្រូវផ្តល់ព័ត៌មានសម្រាប់ទាក់ទងអោយបានពេញលេញ និងត្រឹមត្រូវក្នុងពេលចុះឈ្មោះចូលរួមធ្វើដំណើរ ។ បើអ្នកនឹងធ្វើដំណើរទៅលេងកន្លែងឆ្ងាយ សូមមេត្តាបង្ហាញកន្លែងនោះ ដែលត្រូវ និងលេខទូរស័ព្ទ ដែលយើងអាចទាក់ទងទៅកាន់អ្នកបាន ។ បើមានការរងរបួស ដែលត្រូវការការព្យាបាល គឺបុគ្គលិក YMCA Camp Oakes និង/ឬបុគ្គលិក LBUSD នឹងព្យាយាមទាក់ទងអ្នក ប៉ុន្តែ បើទាក់ទងមិនជួបទេ គឺនឹងមានការផ្តល់សិទ្ធិទៅកាន់វេជ្ជបណ្ឌិត ដែលត្រូវបានជ្រើសរើសឡើងដោយបុគ្គលិក YMCA Camp Oakes និង/ឬ បុគ្គលិក LBUSD ដើម្បីធ្វើការព្យាបាល ស្របតាមសេចក្តីចាំបាច់ និងត្រឹមត្រូវដោយវេជ្ជបណ្ឌិត ។

## ការធានារ៉ាប់រងផ្នែកសុខភាព

ក្នុងនាមជាមាតាបិតា ឬអាណាព្យាបាល គឺអ្នកជាមនុស្សទទួលខុសត្រូវមកលើថ្លៃបង់ការព្យាបាលអ្វីក៏ដោយ ដែលបានកើតឡើងដោយសារតែកូនរបស់អ្នកបានទទួលរងរបួស ឬមានជម្ងឺ នៅពេលចំណាយស្នាក់នៅក្នុងជំរុំសិក្សាក្រៅថ្នាក់ ។ គ្រួសារណា ដែលគ្មានការធានារ៉ាប់រងសុខភាព គឺសូមស្នើសុំអោយចូលមើលនៅតាម www.CoveredCA.com និងគ្រួសារណា ដែលចង់ធ្វើការសម្រេចក្នុងការជ្រើសរើសយកការធានារ៉ាប់រងផ្នែកគ្រោះថ្នាក់សម្រាប់សិស្ស ដែលមាតាបិតាជាអ្នកចេញបង់ថ្លៃ គឺសូមអានមើលនៅតាមគោលការណ៍ណែនាំរបស់ LBUSD សម្រាប់មាតាបិតា និងសិស្ស ។ ខ្ញុំយល់ថា មណ្ឌលអប់រំសាលារៀន ឡុងប៊ីច គ្មានផ្តល់ការធានារ៉ាប់រងអ្វីទេ ដូចជា៖ ការព្យាបាលជម្ងឺ ឬការគេងសម្រាកក្នុងមន្ទីរពេទ្យ ដែលបានកើតឡើងមកកាន់កូនរបស់ខ្ញុំ និងម្លោះហើយ ថ្លៃចេញសងណាមួយក៏ដោយ គឺជាមុខងារទទួលខុសត្រូវសម្រាប់តែខ្លួនខ្ញុំម្នាក់គត់ ។ សូមលៃលកបញ្ជាក់ប្រាប់អំពីព័ត៌មានត្រឹមត្រូវស្តីអំពីការធានារ៉ាប់រងរបស់អ្នកនៅក្នុងក្រដាសបំពេញ ហៅ **Health History Form** ។

## ការបាត់បង់របស់របរ និងរកឃើញវិញ

បទពិសោធន៍របស់សិស្សនៅក្នុងជំរុំសិក្សាក្រៅថ្នាក់ គឺជាឱកាសសម្រាប់សិស្សថ្នាក់ទី5 រៀនទទួលខុសត្រូវក្នុងការមើលថែទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមមេត្តាពិគ្រោះអំពីការចេះទទួលខុសត្រូវ និងការមើលថែទ្រព្យសម្បត្តិរបស់ពួកគេ ។ LBUSD និង YMCA គ្មានធានាខុសត្រូវអ្វីទេចំពោះរបស់របរបាត់បង់ ឬត្រូវបានមនុស្សផ្សេងលួច ។ **កុំផ្ញើរបស់របរមានតម្លៃ**មកជាមួយកូនរបស់អ្នក ។

របស់របរណា ដែលមានមនុស្សផ្សេងបានលួច និងត្រូវបានរកឃើញវិញដោយបុគ្គលិកនៅក្នុងជំរុំសិក្សាក្រៅថ្នាក់ គឺនឹងយកទៅប្រគល់ជូននាយកដឹកនាំជំរុំសិក្សាក្រៅថ្នាក់ ។ របស់របរណា ដែលមិនបានទទួលយកមកវិញអោយទាន់ចុងសប្តាហ៍ គឺនឹងយកទៅប្រគល់ជូននាយកដឹកនាំកម្មវិធីក្នុង LBUSD ហើយនឹងមានការព្យាយាមស្របហេតុផល ដើម្បីប្រគល់វិញទៅកាន់ម្ចាស់ដើម ។ សាលារៀននីមួយៗនឹងស្នើសុំអោយជួយស្វែងរកម្ចាស់ដើម ដើម្បីប្រគល់របស់របរបាត់បង់ទៅកាន់វិញ ប៉ុន្តែ បើរបស់របរបាត់បង់មិនបានទាមទាញមកវិញនោះទេក្នុងរយៈពេល 2 សប្តាហ៍ គឺវាប្រហែលជាយកទៅប្រគល់ជូនអង្គការមនុស្សធម៌ប្រចាំតំបន់ ។

## សេចក្តីសង្ឃឹមទុកមកលើវិន័យ/ការកាន់ភ្ជាប់អាកប្បកិរិយា

សិស្សទទួលការតម្រូវអោយធ្វើតាមវិន័យទាំងអស់របស់មណ្ឌលអប់រំ LBUSD និងសេចក្តីសង្ឃឹមទុករបស់សាលារៀននីមួយៗ និង YMCA Camp Oakes ក្នុងការកាន់ភ្ជាប់នូវអាកប្បកិរិយា និងការរក្សាសុវត្ថិភាព ដែលស្របតាមច្បាប់អប់រំលេខ 48900 ។ ដើម្បីរក្សាសុវត្ថិភាព និងសន្តិសុខបានកាន់តែច្រើន គឺសិស្សនឹងចូលរួមក្នុងការពិគ្រោះ និងការបង្កើតវិន័យសម្រាប់អាកប្បកិរិយានៅតាមខ្ទម ។ គ្រូបង្រៀន LBUSD និងបុគ្គលិក YMCA Camp Oakes នឹងបង្ហាញអំពីការកាន់ភ្ជាប់នូវអាកប្បកិរិយាតាមរយៈប្រើគំរូល្អ និងការរៀបចំប្រើមធ្យោបាយផ្សេងៗ ។ វិន័យជាក់លាក់នៅក្នុងជំរុំសិក្សាក្រៅថ្នាក់ គឺនឹងលើកបង្ហាញទៅកាន់សិស្ស នៅពេលពួកគេទៅដល់ជំរុំសិក្សាក្រៅថ្នាក់ ។ វិន័យសំខាន់ជាងគេ គឺ **1) រក្សាសុវត្ថិភាពគ្រប់ពេលវេលា** និង **2) ទទួលការសប្បាយរីករាយ!** គោលការណ៍ច្បាប់នៅក្នុងជំរុំសិក្សាក្រៅថ្នាក់គាំទ្រមកកាន់វិន័យទាំងអស់នេះ ដែលមានដូចជា៖ នៅជាប់ជាមួយមនុស្សធំ និងសិស្សដូចគ្នាគ្រប់ពេលវេលា បង្ហាញសេចក្តីគោរពមកកាន់គ្នីគ្នា គ្រប់កន្លែង និងរាល់ពេលវេលា (នេះរាប់ទាំងរបស់របរ និងគោលគំនិតនៃមនុស្សដទៃ ធម្មជាតិ សត្វព្រៃ ជាដើម) ។

ការបង្ហាញអាកប្បកិរិយាមិនត្រឹមត្រូវ ដែលមិនស្របតាមសេចក្តីសង្ឃឹមទុកមកលើអាកប្បកិរិយា គឺនឹងធ្វើការកែតម្រូវឡើងវិញ ដើម្បីបង្កើនអាកប្បកិរិយាត្រឹមត្រូវ ការដោះស្រាយបញ្ហា និងការរាប់អានស្និទ្ធស្នាលជាមួយសិស្សដូចគ្នា តាមរយៈការធ្វើទំនាក់ទំនង ដែលមានប្រសិទ្ធិភាព ដើម្បីបង្កើនកម្ពស់ទឹកចិត្តរបស់សិស្ស និងបញ្ជាក់ថា សិស្សទាំងអស់អាចទទួលបាននូវបទពិសោធន៍ដ៏ល្អមួយនៅក្នុងជំរុំសិក្សាក្រៅថ្នាក់ ។ បើសិស្សបង្ហាញអាកប្បកិរិយាមិនត្រឹមត្រូវ គឺវិធានការដូចតទៅនេះនឹងយកមកប្រើ៖

***ជួបប្រជុំជាមួយសិស្ស*** *- ពិគ្រោះអំពីវិន័យ មូលហេតុសម្រាប់វិន័យ និងជួយសិស្សនឹកគិតឡើងវិញអំពីឥទ្ធិពលនៃអំពើរបស់ពួកគេ ។*

***ការជញ្ជឹងគិតដោយសិស្ស និងការណែនាំឡើងវិញ*** *- អ្នកដឹកនាំ ឬបុគ្គលិកក្នុងកន្លែងស្នាក់នៅនឹងពិគ្រោះជាមួយសិស្សអំពីបញ្ហាផ្នែកអាកប្បកិរិយានិងជម្រុញពួកគេអោយធ្វើការជញ្ជឹងគិតអំពីអំពើបង្ហាញរបស់ពួកគេ និងណែនាំពួកគេអោយបែរមកកាន់ភ្ជាប់ជាអាកប្បកិរិយាល្អឡើងវិញ ។ គ្រូបង្រៀននឹងបានទទួលការជម្រាបអំពីស្ថានការ និងធ្វើការពិគ្រោះជាមួយ ។* ***ជំហាន 1***

***កាន់ចិត្តត្រជាក់ និងធ្វើការកែប្រែ*** *- បុគ្គលិកនឹងទុកពេលអោយកុមារជញ្ជឹងគិតអំពីអាកប្បកិរិយារបស់ពួកគេ ឬគ្រាន់តែទុកពេលអោយទទួលការ "ត្រជាក់ចិត្ត" ទំរាំតែមានស្ថានភាពធូរឡើងវិញ ដែលអាចធ្វើការពិគ្រោះជាមួយកុមារបាន ។ បុគ្គលិកនឹងជួយគាំទ្រអោយកុមារចេះធ្វើការសុំទោស និងធ្វើអោយស្ថានភាពកែប្រែ ឬបែរត្រឡប់ទៅដូចដើមវិញ បើអាចធ្វើបាន ។ មាតាបិតានឹងបានទទួលការទាក់ទងទៅកាន់ និងជម្រាបជូនអំពីស្ថានភាព ។* ***ជំហាន 2***

***ជួបប្រជុំជាមួយមាតាបិតា*** *- បុគ្គលិកនឹងប្រើមធ្យោបាយគ្រប់យ៉ាងសម្រាប់ដោះស្រាយបញ្ហាផ្នែកអាកប្បកិរិយារបស់សិស្សនៅជំរុំសិក្សាក្រៅថ្នាក់ ។ មាតាបិតានៃសិស្ស ដែលបង្ហាញការខ្វះខាតផ្នែកឆ្លើយតប ឬកិច្ចការទទួលខុសត្រូវ គឺប្រហែលជានឹងបានទទួលការទាក់ទងតាមរយៈទូរស័ព្ទជាមួយបុគ្គលិក ដើម្បីធ្វើការដោះស្រាយបញ្ហាផ្នែកអាកប្បកិរិយា ។ មាតាបិតានឹងបានទទួលការជួបពិគ្រោះតាមរយៈទូរស័ព្ទជាមួយបុគ្គលិកធ្វើការនៅក្នុងជំរុំសិក្សាក្រៅថ្នាក់ និងបុគ្គលិកសាលារៀនស្តីអំពីអាកប្បកិរិយា ហើយបើបញ្ហានៅតែមានជាបន្ត គឺនឹងបណ្តាលអោយមានការដកឈ្មោះសិស្សចេញពីជំរុំសិក្សាក្រៅថ្នាក់ ។* ***ជំហាន 3***

***ទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន*** *- ចំពោះសិស្ស ដែលមិនអាចគោរពតាមវិន័យ ឬនាំធ្វើអោយមានការប៉ះពាល់ដល់បទពិសោធន៍ទៅកាន់សិស្សដទៃ គឺប្រហែលនឹងបាត់បង់សិទ្ធិ ឬការប្រើប្រាស់នូវឧបករណ៍មួយរយៈពេល ។ បើសិស្សនៅតែបន្តការរំខានមកកាន់ការប្រើវិន័យ គឺពួកគេនឹងប្រហែលបាត់បង់សិទ្ធិក្នុងការចូលរួមជាបន្ថែម និងបញ្ជូនអោយត្រឡប់ទៅផ្ទះវិញ ។* ***មាតាបិតានឹងទទួលខុសត្រូវមកលើការទៅដកយកសិស្សរបស់ខ្លួនត្រឡប់ទៅផ្ទះវិញពីជំរុំសិក្សាក្រៅថ្នាក់*** ។

## <u>ការរំលោភសិទ្ធិកុមារ</u>

បុគ្គលិក LBUSD និង Camp Oakes YMCA បានទទួលការតម្រូវអោយធ្វើជាអ្នករាយការណ៍អំពីការសង្ស័យមកលើការរំលោភសិទ្ធិកុមារ (ដូចជា៖ ការវាយធ្វើបាប ការបំបាក់ទឹកចិត្ត ការជេរស្តី និង/ឬ ការមិនយកចិត្តទុកដាក់មើលថៃ) ទៅកាន់អាជ្ញាធរត្រឹមត្រូវភ្លាមៗ ។

# បញ្ជីត្រួតពិនិត្យសម្រាប់សិស្ស មុនពេលចេញដំណើរ

រៀបចំទុកជាមុន

_______ សុំជំរុញទៅកាន់មាតាបិតារបស់អ្នកអោយឆ្លើយបំពេញព័ត៌មានទាំងអស់តាមរយៈ អនឡាញ ជាពិសេស ទាក់ទងផ្នែកប្រវត្តិសុខភាព និងការយល់ព្រម ។
_______ ឃ្លាំមើលសុខភាពរបស់សិស្សរាល់លើក មុននឹងដល់ពេលចេញដំណើរ ។ សិស្សនឹងមិនអាចចូលរួមបានទេ បើមានជម្ងឺមិនស្របល័ក្ខខ័ណ្ឌរបស់ជំរុំសិក្សាក្រៅថ្នាក់ ។
_______ **ថ្នាំពេទ្យ គឺត្រូវផ្តល់ជូនអ្នកគ្រូពេទ្យ ដោយមានឈ្មោះសិស្សភ្ជាប់មកជាមួយផង** និងឯកសារតម្រូវចាំបាច់ផ្សេងៗក្នុងពេលមួយសប្តាហ៍ មុននឹងការចេញដំណើរទៅកាន់ជំរុំសិក្សាក្រៅថ្នាក់ ។

ថ្ងៃអ្នកចេញដំណើរ

_______ នាំយក វ៉ាលីស ប្រដាប់គេង និងគ្រឿងប្រើប្រាស់ផ្សេងៗទៀតរបស់សិស្សមកជាមួយ ដោយមានឈ្មោះរបស់សិស្សសរសេរនៅពីលើយ៉ាងច្បាស់ផង ។
_______ **ថ្នាំពេទ្យមិនត្រូវរៀបដាក់ក្នុងថង់សំលៀកបំពាក់របស់សិស្សនោះទេ** - ថ្នាំពេទ្យទាំងអស់ត្រូវផ្តល់ជូនអ្នកគ្រូពេទ្យក្នុងពេលមួយសប្តាហ៍មុនការចេញដំណើរ ។
_______ **ស្លៀកខោជើងវែង** (មិនមែនខោយឺតជើងវែងនោះទេ) និងពាក់ស្បែកជើងសមលក្ខណៈសម្រាប់ងាយដើរ/ដើរឡើងទួល ។

## <u>បញ្ជីរបស់របរប្រើប្រាស់សម្រាប់ដាក់ទៅជាមួយ</u>

***បញ្ជាក់អោយច្បាស់ថា ឈ្មោះរបស់អ្នក និងឈ្មោះសាលារៀនពិតជាមានសរសេរច្បាស់មែននៅតាម វ៉ាលីស ទាំងអស់ ។***

សិស្សអាចយកបានដល់ទៅ 3 វ៉ាលីសៈ

1) កាតាបស្ពាយតូច (មានខ្សែចងភ្ជាប់) សម្រាប់ស្ពាយជាមួយនៅតាមរថយន្តក្រុង

2) វ៉ាលីស សម្រាប់ដាក់សំលៀកបំពាក់ភាគច្រើន

3) កម្រាលក្រាស់សម្រាប់ក្រាលគេង

*សិស្សគួរតែកាន់បាននូវចំនួន វ៉ាលីស ទាំង 3 ទៅមកពីរថយន្តក្រុង នៅពេលធ្វើដំណើរមួយជើងទៅកាន់ខ្ទម*

**វ៉ាលីស #1: កាតាបស្ពាយសាលារៀនតូចមួយ** - កាន់ភ្ជាប់នៅពេលជិះរថយន្តក្រុង
កាតាបនេះគួរនៅជាប់ជាមួយអ្នកគ្រប់ពេលវេលា ។

- ដបទឹក ដែលមានឈ្មោះរបស់អ្នក
- កូនពិល
- ស្រោមដៃ
- ស្រោមជើងបន្ថែម
- អាវរងា
- អាវ ជេកិត/អាវភ្លៀង (ការពារខ្យល់/មិនសើមទទឹក)
- អាវយឺតដៃវែងក្រាស់
- មួកពាក់សម្រាប់ធ្វើអោយកក់ក្តៅក្បាល

**វ៉ាលីស #2: កម្រាលសម្រាប់ក្រាលគេង - អាចយកប្រើបាន បន្ទាប់ពីពេលទទួលអាហារល្ងាចផុតទៅ**
ខ្នើយមួយ និងកម្រាលគេងមួយសម្រាប់ដាក់ក្រាលលើថង់ប្លាស្ទិកធំ (ការពារពេលមានអាកាសធាតុប្រែ) ។ សរសេរឈ្មោះរបស់អ្នក និងសាលារៀននៅពីលើ ។ កម្រាល និងភួយក្រាស់ អាចប្រើបានជាកម្រាលក្រាលគេង ។

**វ៉ាលីស #3: វ៉ាលីស/កាបូបយួរធំ - អាចយកប្រើបាន បន្ទាប់ពីពេលទទួលអាហារល្ងាចផុតទៅ**
ស្នើសុំអោយដាក់គ្រឿងសំអាតខ្លួនក្នុងថង់ ziploc ធំមួយ ។

## របស់របរចាំបាច់៖

_______ ប្រេងលាបបបូរមាត់/ធ្វើអោយសើមមាត់

_______ ស្បែកជើង (2 គូ) ត្រូវមានគម្របបិទម្រាមជើង

_______ ខោជើងវែង (មិនមែនខោយឺតជើងវែង ឬខ្លី) (3 គូ)

_______ អាវដៃវែងក្រាស់ (1)

_______ អាវយឺតដៃខ្លី (5)

_______ ស្រោមដៃ

_______ មួកពាក់ងំក្បាល (1)

_______ ស្រោមជើង (ចង់បានជាតិកប្បាស ឬរោមចៀម) (6- 8 គូ)

_______ ថ្នាំ និងច្រាសដុសធ្មេញ

_______ ច្រាស ឬស្និតសិតសក់

_______ ប្រេងការពារស្បែក (មិនមែនប្រើបាញ់)

_______ ស្បែកជើងពាក់ងូតទឹក

_______ អាវយឺតក្រាស់ (2)

_______ សំលៀកបំពាក់គេង

_______ អាវដៃវែង (2)

_______ ខោអាវទ្រនាប់ (8 គូ)

_______ ថ្នាំបំបាត់ក្លិនក្លៀក (មិនមែនថ្នាំបាញ់)

_______ មួកមានគែម (1)

_______ សាប៊ូ និងសាប៊ូកក់សក់

_______ កន្សែងជូតខ្លួន

## របស់របរដាក់ទៅជាមួយ ស្របតាមការជម្រើស៖

_______ ថង់ដាក់សំលៀកបំពាក់បោក (ក្រខ្វក់)

_______ ម៉ាស៊ីនថតរូប (ប្រើហើយ បោះចោល)

_______ វ៉ែនតាខ្មៅការពារពន្លឺ និងកំដៅថ្ងៃ

_______ សៀវភៅអាន

_______ រូបកូនតុក្កតាសម្រាប់ឱប

*នៅក្នុងជុំវិសិក្សាក្រៅថ្នាក់ គឺជូនកាលទៅ អាចប្រែជារងាខ្លាំង ដូច្នេះ យើងជម្រុញអោយអ្នករៀបដាក់សំលៀកបំពាក់ច្រើនស្រទាប់មកជាមួយ ។ ការធ្វើដូច្នេះ គឺជួយអ្នកអោយពាក់ជាច្រើនស្រទាប់បាន នៅពេលមានភាពត្រជាក់ និងដោះចេញនៅពេលមានភាពក្តៅ ដើម្បីការពារកុំអោយអ្នកត្អូញត្អែថា "ក្តៅណាស់ នៅពេលខ្ញុំពាក់អាវដៃវែងក្រាស់ ប៉ុន្តែ ត្រជាក់ នៅពេលខ្ញុំដោះវាចេញ" ។*

*សិស្សគួរពាក់ដល់ទៅ 5 ស្រទាប់នៅដងខ្លួនខាងលើ (អាវយឺតក្នុងដៃវែង អាវយឺតក្រាស់ អាវរងា អាវការពារទឹកមិនអោយសើមខ្លួន) និង 2 ស្រទាប់នៅផ្នែកខាងក្រោម (ខោយឺតក្នុងដែលមានជើងវែង និងខោជើងវែងក្រាស់) ។*

*សូមចំណាំថា មានភាពខុសគ្នាច្រើនណាស់រវាងអាវរងា ឬ អាវភ្លៀង ផនចូ ដែលការពារទឹកមិនអោយចូលខ្លួន និងមួយទៀត គឺគ្រាន់តែការពារទឹក ។ បើអ្នកដាក់ផ្ញើអាវរងាតាមកូនរបស់អ្នក ដែលគ្រាន់តែការពារទឹក គឺទឹកនឹងជ្រាបចូលយ៉ាងលឿន ហើយកូនរបស់អ្នកនឹងទទួលភាពរងា និងសើមខ្លួន!*

***កុំភ្លេចសរសេរឈ្មោះរបស់អ្នក និងឈ្មោះសាលារៀនរបស់អ្នកនៅលើរបស់របរប្រើប្រាស់ទាំងអស់ ។**

**LBUSD និង YMCA CAMP OAKES គ្មានការធានាខុសត្រូវអ្វីទេមកលើរបស់របរបាត់បង់ ឬត្រូវបានមនុស្សផ្សេងលួច ។**

**យើងនឹងព្យាយាមប្រគល់របស់របរជូនម្ចាស់ដើមវិញ នៅពេលណាបានរកឃើញមកវិញ ។***